**អគ្គលេខាធិការ**
**អង្គការសហប្រជាជាតិ**

ទីក្រុងញូវយ៉ក

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

# សេចក្តីថ្លែងការណ៍ដោយអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លោក Stephane Dujarric អ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ

លោកអគ្គលេខាធិការបានកត់សម្គាល់ពីការចេញសាលក្រមសំណុំរឿង ០០២/០២ នៅថ្ងៃនេះ ដោយអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ប្រឆាំងនឹង លោក នួន ជា អនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។ លោក ខៀវ សំផន អតីតប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ។

សាលក្រមនៅថ្ងៃនេះ បង្ហាញថាជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងបំផុត អាចចាប់ឲ្យទទួលខុសត្រូវហើយ សូម្បីតែកន្លងផុតទៅអស់រយៈពេលរាប់ទសវត្សរ៍ ក្រោយពីបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះហើយក៏ដោយ។

ការគិតគូរយកចិត្តទុកដាក់របស់អគ្គលេខាធិការចំពោះជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលជនជាប់ចោទទាំងពីររូបនេះ ត្រូវគេរកឃើញថាមានពិរុទ្ធភាព។

អគ្គលេខាធិការ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការលះបង់ និងការខិតខំប្រឹងប្រែងរបស់ជនគ្រប់រូបដែលចូលរួមក្នុងការងារដ៏សំខាន់របស់ អ.វ.ត.ក ដើម្បីស្វែងរកយុត្តិធម៌ និងគណនេយ្យភាពនៅប្រទេសកម្ពុជា។ លោកអគ្គលេខាធិការសូមអំពាវនាវឲ្យរដ្ឋសមាជិកបន្តផ្តល់ការគាំទ្រតទៅទៀតដល់ អ.វ.ត.ក។